## គោលការណ៍ការពារ (protective principle)

តាមគោលការណ៍នេះ រដ្ឋមានយុត្តាធិការលើ ជនបរទេសនៅក្រៅប្រទេស ដែលប្រព្រឹត្តបទល្មើស ប៉ះប្រយោជន៍ចម្បងរបស់រដ្ឋ (vital interest) ដូចជាបទល្មើសពាក់ព័ន្ធរូបិយប័ណ្ណ។ ច្បាប់អន្តរជាតិ ទទួលស្គាល់គោលការណ៍ការពារនេះ ទោះបីជាយ៉ាងនេះក្តី ពាក្យ«ផលប្រយោជន៍ចម្បង» កំណត់ដោយរដ្ឋ តាមឆន្ទានុសិទ្ធិ។

តុលាការជាតិជាច្រើន ក៏បានទទួលយកគោលការណ៍នេះដែរ។ ការកាត់ទោស លោក Eichmann ត្រូវបានចាប់ជម្រិតពីប្រទេស អាហ្សង់ទីន ដោយតុលាការអ៊ីស្រាអែល ជាឧទាហរណ៍មួយនៃការអនុវត្ត យុត្តាធិការតាមគោលការណ៍នេះ ដោយតុលាការអ៊ីស្រាអែល (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p.474)។